NAPCA

**The National Asian Pacific Center on Aging (NAPCA-**មជ្ឈមណ្ឌលជាតិអាស៊ីប៉ាស៊ីភិចសម្រាប់មនុស្សចាស់) សូមបង្ហាញជូន ៖

---

# ការទទួលបានជំនួយសម្រាប់ចំណាយលើការថែទាំសុខភាព និងថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់អ្នក

បេសកកម្មរបស់ National Asian Pacific Center on Aging គឺដើម្បីបំរើក្នុងនាមជាអង្គការនាំមុខរបស់ជាតិផ្តែកតស៊ូមតិ ដែលមានឆន្ទៈលើកកម្ពស់សេចក្តីថ្លៃថ្នូរ សុខុមាលភាព និងគុណភាពនៃជីវិតរបស់ជនជាតិអាមេរិកាំងដើមកំណើតអាស៊ី (APA) ពេលពួកគេឈានចូលវ័យចាស់ជរា ។

កូនសៀវភៅនេះ មានរួមបញ្ចូលនូវព័ត៌មាន លើចំណុចដូចខាងក្រោម ៖

- Extra Help (ជំនួយបន្ថែម) សម្រាប់បង់ថ្លៃថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់ Medicare
- Medicare Savings Programs (កម្មវិធីសន្សំ Medicare)
- Medicaid
- State Prescription Assistance Programs (SPAP-កម្មវិធីជំនួយលើថ្លៃថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់រដ្ឋ)
- Programs of All-Inclusive Care for the Elderly (PACE-កម្មវិធីការថែទាំទាំងអស់ សម្រាប់មនុស្សចាស់)
- អត្ថប្រយោជន៍ Supplemental Security Income (SSI-ប្រាក់ចំណូលសុវត្ថិភាពបន្ថែម)
- Children's Health Insurance Program (កម្មវិធីធានារ៉ាប់រងសុខភាពកុមារ)

ចូររក្សាទុកនូវព័ត៌មានទាំងអស់ដែលអ្នកបានទទួលពី Medicare, Social Security (សន្តិសុខសង្គម) ផែនការសុខភាព ឬផែនការចំណាយលើថ្នាំពេទ្យតាមវេជ្ជបញ្ជា Medicare  អ្នកធានារ៉ាប់រង Medigap ឬការធានារ៉ាប់រងរបស់និយោជក ឬសហជីពរបស់អ្នក ។  ព័ត៌មានទាំងនេះ អាចមានរួមបញ្ចូលទាំង សេចក្តីជូនដំណឹងពីការផ្តល់ជំនួយ ឬការបដិសេធមិនផ្តល់ជំនួយ ការជូនដំណឹងអំពីការផ្លាស់ប្តូរប្រចាំឆ្នាំ ការជូនដំណឹងអំពីការគ្របដណ្តប់លើ ថ្លៃថ្នាំពេទ្យតាមវេជ្ជបញ្ជា ដែលអាចយកមកធ្វើជាឥណទានបាន ឬសេចក្តីជូនដំណឹងសង្ខេបអំពី Medicare ។ អ្នកអាចត្រូវការឯកសារទាំងនេះ សម្រាប់ដាក់ពាក្យសុំការធានារ៉ាប់រងពីកម្មវិធីដែលត្រូវបានពន្យល់ជូនក្នុងផ្នែកនេះ ។ អ្នកក៏ត្រូវរក្សាទុកនូវសំណៅថតចម្លងនៃពាក្យសុំនានាដែលអ្នកបានដាក់ជូនផងដែរ។

## កម្មវិធីសម្រាប់អ្នកដែលមានប្រាក់ចំណូល និង ធនធានតិចតួច

បើអ្នកមានប្រាក់ចំណូល និងធនធានតិចតួច អ្នក ប្រហែលជាមានលក្ខណៈសម្បត្តិ បានទទួលជំនួយបង់ ថ្លៃលើសេវាថែទាំសុខភាពមួយចំនួន និងការចំណាយ លើថ្លៃទិញថ្នាំពេទ្យតាមវេជ្ជបញ្ជា ។

តំបន់កោះវ៉ឺជិន កោះគួម អាមេរិកាំងសាម៉ូអា តំបន់ កុម៉ង់វៀលនៃរដ្ឋព័រតូរីកូ និងតំបន់កុម៉ន់វៀលនៃដែន កោះម៉ារៀណាខាងជើង មានផ្តល់ឲ្យពលរដ្ឋរបស់ខ្លួន នូវជំនួយ សម្រាប់ចេញថ្លៃទិញថ្នាំពេទ្យ Medicare ។ ជំនួយនេះ គឺមិនដូចគ្នាទៅនឹង Extra Help (ជំនួយ បន្ថែម) ដូចមានរៀបរាប់ជូនខាងក្រោមឡើយ ។

# Extra Help ចំពោះការបង់ចំណាយលើថ្លៃថ្នាំពេទ្យតាមវេជ្ជបញ្ជា (ជំពូក ឃ)

អ្នកអាចមានលក្ខណៈសម្បត្តិបានទទួល Extra Help ដែលត្រូវបានគេស្គាល់ផងដែរថាជា low-income subsidy (LIS-ជំនួយជាប្រាក់ដល់អ្នកដែលមានប្រាក់ចំណូលទាប) ពី Medicare ដើម្បីចំណាយលើថ្លៃទិញថ្នាំពេទ្យតាមវេជ្ជបញ្ជា ប្រសិនបើប្រាក់ចំណូលប្រចាំឆ្នាំ និងធនធានរបស់អ្នក មានចំនួនទាបជាងចំនួនមួយដែលបានកំណត់ ក្នុងឆ្នាំ២០១០ ដូចខាងក្រោម ៖

- បុគ្គលទោល—ប្រាក់ចំណូលមានចំនួនតិចជាង $ ១៦៣៣៥ និងធនធានដែលមានតម្លៃទាបជាង $ ១២៦៤០
- អ្នកដែលរៀបការ ហើយរស់នៅជាមួយគ្នា ហើយមិនមានអ្នកនៅក្នុងបន្ទុក—មានប្រាក់ចំណូលទាបជាង $២២០៦៥ និងធនធាន មានតម្លៃទាបជាង $២៥២៦០

ចំនួនទាំងនេះ អាចផ្លាស់ប្តូរក្នុងឆ្នាំខាងមុខ ។ អ្នកអាចមានលក្ខណៈសម្បត្តិបានទទួលជំនួយ បើទោះបីជាអ្នកមានប្រាក់ចំណូល ខ្ពស់ក៏ដោយ (ដូចជាថាតើអ្នកនៅធ្វើការនៅឡើយ ឬមួយថាតើអ្នករស់នៅក្នុងរដ្ឋអាឡាស្កា ឬរដ្ឋហាវ៉ៃ ឬមានអ្នកនៅក្នុងបន្ទុករស់នៅជាមួយ) ។ ធនធាន មានរួមទាំងប្រាក់នៅក្នុងគណនីសែក ឬគណនីសន្សំ ប័ណ្ណភាគហ៊ុន និងប័ណ្ណប្រាក់រដ្ឋាភិបាល ។ ធនធានទាំងនោះ មិនរាប់បញ្ចូលនូវផ្ទះ រថយន្តរបស់របរប្រើប្រាស់ក្នុង ផ្ទះ ដីបញ្ចុះសព ការចំណាយលើការបញ្ចុះសពដែលមានចំនួនរហូតដល់ $១៥០០ (សម្រាប់សពមួយរូប) ឬការធានារ៉ាប់រងជីវិត របស់អ្នកឡើយ ។

បើអ្នកមានលក្ខណៈសម្បត្តិបានទទួល Extra Help ហើយអ្នកបានចូលរួមក្នុងផែនការថ្នាំពេទ្យ Medicare អ្នកនឹងបានទទួលនូវជំនួយដូចខាងក្រោម ៖

- ជួយក្នុងការចេញថ្លៃទិញថ្នាំពេទ្យរបស់ផែនការ Medicare ប្រចាំខែ ការចំណាយណាមួយដែល

អាចកាត់ចេញ បានប្រចាំឆ្នាំ សហធានារ៉ាប់រង និងការចំណាយរួមគ្នា

- មិនមានប្រហោងនៃការធានារ៉ាប់រង
- មិនមានការពិន័យក្នុងការចុះឈ្មោះចូលជាសមាជិកយឺតយ៉ាវ

អ្នកមានលក្ខណៈសម្បត្តិដោយស្វ័យប្រវត្តិ ដើម្បីបានទទួល Extra Help ប្រសិនបើអ្នកមានការធានារ៉ាប់រងសុខភាពពី Medicare ហើយស្ថិតក្នុងលក្ខ័ណ្ឌណាមួយក្នុងចំណោមលក្ខ័ណ្ឌនានាដូចខាងក្រោម ៖

- អ្នកមានការធានារ៉ាប់រងពេញលេញពី Medicaid។
- អ្នកបានទទួលជំនួយពីកម្មវិធី Medicaid ក្នុងរដ្ឋអ្នក ដើម្បីបង់ចំណាយសរុបនៃជំពូក ខ របស់អ្នក (ក្នុង Medicare Savings Program-កម្មវិធីសន្សំ Medicare) ។
- អ្នកបានទទួលអត្ថប្រយោជន៍ Supplemental Security Income (SSI-ប្រាក់ជំនួយសុវត្ថិភាពបន្ថែម) ។

ដើម្បីឲ្យអ្នកបានដឹងថា អ្នកមានលក្ខណៈសម្បត្តិដោយស្វ័យប្រវត្តិក្នុងការទទួល Extra Help Medicare នឹងផ្ញើឲ្យអ្នកនូវលិខិតពណ៌ស្វាយមួយច្បាប់មកឲ្យអ្នក ដែលអ្នកគួររក្សាវាទុក ជាឯកសាររបស់អ្នក ។ អ្នកមិនចាំបាច់ដាក់ពាក្យសុំ Extra Help ឡើយ បើអ្នកបានទទួលលិខិតពណ៌ស្វាយរួចហើយ ។

- បើអ្នកមិនទាន់បានចុះឈ្មោះចូលក្នុងផែនការថ្នាំពេទ្យ Medicare ទេ អ្នកត្រូវតែចូលរួម ក្នុងផែនការណាមួយ ដើម្បីបានទទួល Extra Help ។
- បើអ្នកមិនចូលរួមក្នុងផែនការថ្នាំពេទ្យ Medicare ទេ Medicare អាចចុះឈ្មោះឲ្យអ្នកចូលរួមក្នុងផែនការណាមួយ ។ បើ Medicare បានចុះឈ្មោះឲ្យអ្នកចូលរួមក្នុងផែនការណាមួយ Medicare នឹងផ្ញើ ឲ្យអ្នកនូវលិខិតពណ៌លឿង ឬពណ៌បៃតង ដើម្បីប្រាប់អ្នកឲ្យបានដឹងថា តើការធានារ៉ាប់រង

របស់អ្នក នឹងចាប់ផ្តើមនៅពេលណា ។

- ផែនការនីមួយៗ មានការគ្រប់ដណ្តប់លើប្រភេទថ្នាំពេទ្យខុសៗគ្នា ។ ត្រូវឆែកមើល ដើម្បីបានដឹងថា ផែនការ ដែលអ្នកបានចុះឈ្មោះចូលជាសមាជិក មានការគ្រប់ដណ្តប់លើប្រភេទថ្នាំពេទ្យដែលអ្នកប្រើ ហើយថាតើ អ្នកអាចទិញថ្នាំទាំងនោះពីឱសថស្ថានដែលអ្នកចង់ដែរឬទេ។ ចូរធ្វើការប្រៀបធៀបជាមួយនឹងផែនការផ្សេងទៀត ដែលមានផ្តល់សេវានៅក្នុងតំបន់របស់អ្នក ។
- បើអ្នកបានទទួល Extra Help អ្នកអាចប្តូរទៅកាន់ផែនការថ្នាំពេទ្យផ្សេងទៀតរបស់ Medicare បានគ្រប់ពេល ។ ការធានារ៉ាប់រងរបស់អ្នក នឹងចូលជាធរមាន នៅថ្ងៃដំបូង នៃខែបន្ទាប់ ។
- បើអ្នកមានការធានារ៉ាប់រងពី Medicaid ហើយរស់នៅក្នុងអគារ ស្ថាប័នណាមួយ (ដូចជាផ្ទះផ្តល់ការថែទាំអ្នកជំងឺ) អ្នកនឹងមិនចាំបាច់ចំណាយមួយ

កាក់មួយសេនឡើយ សម្រាប់ថ្លៃថ្នាំពេទ្យដែល ស្ថិតក្រោមការ ធានារ៉ាប់រង ។

បើអ្នកមិនចង់ចូលរួមក្នុង ផែនការថ្នាំពេទ្យកម្មវិធី Medicare ទេ (ឧទាហរណ៍ ដោយសារថាអ្នកត្រូវការតែ ការធានារ៉ាប់រង របស់និយោជក ឬសហជីពរបស់អ្នក) សូមហៅទូរស័ព្ទមកជួបជាមួយនឹងតំណាងកម្មវិធីដែល មានសរសេរនៅក្នុងលិខិត របស់អ្នក ឬហៅមកកាន់ លេខ 1-800-MEDICARE (1-800-633-4227) ។ សម្រាប់ អ្នកប្រើទូរស័ព្ទក្តារចុច TTY គួរហៅមកកាន់លេខ 1-877-486-2048 ។ ចូរប្រាប់ពួកគេឲ្យបានដឹងថាអ្នកមិន ចង់ចូលរួមក្នុងផែនការថ្នាំពេទ្យ Medicare ទេ (អ្នក “សម្រេចចិត្តមិនចូលរួម”) ។ បើអ្នកនៅតែបន្តមាន លក្ខណ:សម្បត្តិ បានទទួល Extra Help ឬមួយថាការ ធានារ៉ាប់រងរបស់និយោជក ឬសហជីពរបស់អ្នក គឺជា ការគ្របដណ្តប់លើថ្លៃថ្នាំពេទ្យតាមវេជ្ជបញ្ជា ដែលអាច យកមកធ្វើជាឥណទានបាន គឺមានន័យថា អ្នកមិន

ចាំបាច់ត្រូវបង់ប្រាក់ពិន័យ ពីការចុះឈ្មោះយឺតឡើយ បើអ្នកសម្រេចចិត្តចូលរួមនាពេលក្រោយ ។

បើអ្នកមានការធានារ៉ាប់រងសុខភាពរបស់និយោជក ឬសហជីព ហើយអ្នកចូលរួមក្នុងផែនការថ្នាំពេទ្យ Medicare អ្នកអាចបាត់បង់ការធានារ៉ាប់រងលើការចេញថ្លៃថ្នាំពេទ្យរបស់និយោជក ឬសហជីព ហើយអាចបាត់បង់ដល់ការធានារ៉ាប់រងសុខភាពផងដែរ បើទោះបីជាអ្នកមានលក្ខណៈសម្បត្តិបានទទួល Extra Help កដោយ ។ អ្នកនៅក្នុង បន្ទុករបស់អ្នក ក៏អាចបាត់បង់ការធានារ៉ាប់រងនេះផងដែរ ។ ចូរហៅទូរស័ព្ទទៅជួបនឹងអ្នកចាត់ ចែងអត្ថប្រយោជន៍និយោជក របស់អ្នក ដើម្បីបានដឹងព័ត៌មានបន្ថែម នៅមុនពេលអ្នកសម្រេចចិត្តចូលរួម ។

បើអ្នកមិនមានលក្ខណៈសម្បត្តិ ក្នុងការ ទទួលបាន Extra Help ជាស្វ័យប្រវត្តិទេ អ្នកអាចដាក់ពាក្យសុំជំនួយបាន ៖

■ ចូររកព័ត៌មានក្នុងគេហទំព័រ www.socialsecurity.gov

ដើម្បីដាក់ពាក្យសុំអនឡាញ ។

■ ចូរហៅទូរស័ព្ទមកកាន់ Social Security តាមរយៈលេខ 1-800-772-1213 (មានអ្នកបកប្រែភាសា នៅរង់ចាំបំរើ តាមការស្នើសុំ) ដើម្បីដាក់ពាក្យតាមទូរស័ព្ទ ឬ ដើម្បីបានទទួលពាក្យសុំចូលជាសមាជិក ។ សម្រាប់អ្នកប្រើទូរស័ព្ទ ក្តារចុច TTY គួរហៅមកកាន់លេខ 1-800-325-0778 ។

■ ចូរធ្វើដំណើរមកកាន់ការិយាល័យ State Medical Assistance (ជំនួយវេជ្ជសាស្ត្ររបស់រដ្ឋ) (Medicaid) ។ ឬ ហៅទូរស័ព្ទមកកាន់លេខ 1-800-MEDICARE (1-800-633-4227) ហើយនិយាយថា “Medicaid” ដើម្បីបានទទួលលេខទូរស័ព្ទ ឬទស្សនាគេហទំព័រ www.medicare.gov ។ សម្រាប់អ្នកប្រើទូរស័ព្ទក្តារចុច TTY គួរហៅមកកាន់លេខ 1-877-486-2048 ។

កំណត់ចំណាំ ៖ អ្នកអាចដាក់ពាក្យសុំ Extra Help បានគ្រប់ពេល ។ ជាមួយនឹងការយល់ព្រមរបស់អ្នក Social

Security នឹងបញ្ជូនព័ត៌មានទៅកាន់រដ្ឋរបស់អ្នក ដើម្បីចាប់ផ្តើមដំណើរការពាក្យសុំសម្រាប់ Medicare Savings Program ។

តម្លៃថ្នាំពេទ្យ សម្រាប់មនុស្សភាគច្រើន ដែលមានលក្ខណ: សម្បត្តិ ទទួលបាន Extra Help នឹងមិនមានចំនួនច្រើនជាង $២.៥០ សម្រាប់ថ្លៃថ្នាំពេទ្យទូទៅមួយមុខៗ និង $៦.៣០ សម្រាប់ថ្នាំពេទ្យដែលមានយីហោនីមួយៗ ។ ចូរអានព័ត៌មាននៅក្នុងលិខិត Extra Help ដែលអ្នកបានទទួល ឬទាក់ទងជាមួយនឹងតំណាងកម្មវិធីរបស់អ្នក ដើម្បីបានដឹងពីតម្លៃពិតប្រាកដរបស់អ្នក ។ ដើម្បីបានចម្លើយលើសំណួររបស់អ្នកអំពី Extra Help និងជួយក្នុងការជ្រើសរើសយកផែនការណាមួយ អ្នកអាច ហៅទូរស័ព្ទមកកាន់លេខ 1-800-MEDICARE ។ Medicare បានទទួលព័ត៌មានពីរដ្ឋរបស់អ្នក ឬពី Social Security ដែលប្រាប់ថា តើអ្នកមានលក្ខណ:សម្បត្តិបានទទួល Extra Help ឬទេ ។ ប្រសិនបើ Medicare មិនមាន

ព័ត៌មានដែលត្រឹមត្រូវ អ្នកប្រហែលជាបង់ការចំណាយក្នុងចំនួនមិនត្រឹមត្រូវ សម្រាប់ថ្លៃថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់ អ្នកដែលបានទទួលការធានារ៉ាប់រង ។

បើអ្នកមានលក្ខណៈសម្បត្តិបានទទួល Extra Help ដោយស្វ័យប្រវត្តិ អ្នកអាចបង្ហាញផែនការថ្នាំពេទ្យរបស់អ្នក នូវលិខិតពណ៌ស្វាយ ពណ៌លឿង ឬពណ៌បៃតង ដែលអ្នកបានទទួលពី Medicare ជាភស្តុតាងបង្ហាញថា អ្នកមាន លក្ខណៈសម្បត្តិ ទទួលបានជំនួយនេះ។ បើអ្នកបានដាក់ពាក្យសុំ Extra Help អ្នកអាចបង្ហាញលិខិត "លិខិតជូនដំណឹងពីការផ្តល់ជំនួយ" របស់អ្នក ដែលអ្នកបានទទួលពី Social Security ជាភស្តុតាងថាអ្នកមានលក្ខណៈសម្បត្តិ ដើម្បីបានទទួលជំនួយ ។

អ្នកក៏អាចផ្តល់ឲ្យតំណាងកម្មវិធីរបស់អ្នកនូវ ឯកសារណាមួយដូចខាងក្រោម (ត្រូវបានគេហៅផងដែរថា

“Best Available Evidence-ភស្តុតាងប្រសើរបំផុតដែល មាន”) ជាភស្តុតាងបញ្ជាក់ថា អ្នកមានលក្ខណៈសម្បត្តិ បានទទួល Extra Help ។ តំណាងកម្មវិធីរបស់អ្នកត្រូវតែ ទទួលយកឯកសារទាំងនេះ ។ ចំណុចនីមួយៗដែល មានសរសេរ ជូនខាងក្រោម បង្ហាញថា អ្នកមានសិទ្ធិ បានទទួលជំនួយពី Medicaid ក្នុងខែណាមួយ បន្ទាប់ពី ខែមិថុនា ២០១០ ។ បើអ្នកនៅមិនទាន់បានចុះឈ្មោះ ចូលជាសមាជិកក្នុងផែនការថ្នាំពេទ្យ Medicare ហើយ បានចំណាយលើថ្លៃថ្នាំពេទ្យ តាមវេជ្ជបញ្ជាដោយប្រាក់ របស់អ្នក នៅពេលអ្នកមានលក្ខណៈសម្បត្តិបានទទួល Extra Help អ្នកប្រហែលជាអាចបានទទួលមកវិញ នូវ ចំណែកដែលអ្នកបានចំណាយ ។ ចូររក្សាទុកប័ណ្ណបង់ ប្រាក់ទាំងអស់របស់អ្នក ហើយហៅទូរស័ព្ទ មកកាន់ កម្មវិធី Medicare’s Limited Income Newly Eligible Transition (NET-ការមានសិទ្ធិថ្មីជាអន្តរកាលរបស់ Medicare ចំពោះអ្នកដែលមានប្រាក់ចំណូលតិច) តាម រយៈទូរស័ព្ទលេខ 1-800-783-1307 ដើម្បីបានទទួល

ព័ត៌មានបន្ថែម ។ សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទក្តារចុច TTY គួរហៅមកកាន់លេខ 1-877-801-0369 ។ សម្រាប់ព័ត៌មានបន្ថែម ចូរ អានព័ត៌មានលើគេហទំព័រ http://go.usa.gov/loo ដើម្បីពិនិត្យមើលព័ត៌មានពិតដែលមានចំណងជើងថា “Are You Paying the Right Amount for Your Prescriptions?-តើអ្នកបានបង់ចំណាយក្នុងចំនួនមួយដែលត្រឹមត្រូវ សម្រាប់ថ្លៃថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់អ្នកដែរឬទេ? ” ។ អ្នកក៏អាចហៅទូរស័ព្ទមកកាន់លេខ 1-800-MEDICARE (1-800-633-4227) ដើម្បីចង់ដឹងថា តើគេអាចផ្ញើឯកសារនេះមួយច្បាប់ មកឲ្យអ្នកតាមប្រៃសនីយបានដែរឬទេ ។ សម្រាប់អ្នកប្រើទូរស័ព្ទ ក្តារចុច TTY គួរហៅមកកាន់លេខ 1-877-486-2048 ។

## Medicare Savings Programs (កម្មវិធីសន្សំ Medicare) (ជួយចេញថ្លៃ Medicare )

នៅតាមរដ្ឋនានា មានកម្មវិធី ដែលជួយចេញថ្លៃសរុបការធានារ៉ាប់រងលើករណី Medicare និងក្នុងករណីមួយចំនួន ក៏ប្រហែលជាអាច ជួយចេញថ្លៃជំពូក ក និង ជំពូក ខ ដែលត្រូវកាត់សម្រាប់ឲ្យអ្នកចេញថ្លៃ សហធានារ៉ាប់រង និងការចំណាយរួមគ្នាផងដែរ ។ កម្មវិធីទាំងនេះ ជួយដល់អ្នកស្ថិតក្នុងកម្មវិធី Medicare អាចធ្វើការសន្សំប្រាក់បានក្នុងមួយឆ្នាំៗ ។

ដើម្បីមានលក្ខណ:សម្បត្តិអាចចូលរួមបានក្នុង Medicare Savings Program អ្នកត្រូវតែស្ថិតក្នុងលក្ខ័ណ្ឌទាំង អស់ដូចមានចែងខាងក្រោម ៖

- មានការធានារ៉ាប់រងពីជំពូក ក
- អ្នកនៅលីវ ដែលមានប្រាក់ចំណូលប្រចាំខែតិចជាង $១២៤៦ និងមានធនធាន ដែលមានតម្លៃ

តិចជាង $៦៦៨០

- អ្នករៀបការ ហើយរស់នៅជាមួយគ្នា មានប្រាក់ចំណូលប្រចាំខែតិចជាង $១៦៧៥ និងមានធនធាន ដែលមានតម្លៃតិចជាង $១០០២០

កំណត់ចំណាំ ៖ ចំនួនទាំងនេះ អាចផ្លាស់ប្តូរក្នុងឆ្នាំនីមួយៗ ។ រដ្ឋជាច្រើន ធ្វើការគណនាប្រាក់ចំណូល និងធនធាន របស់អ្នក ដោយប្រើវិធីផ្សេងៗគ្នា ដូច្នេះ អ្នកអាចមានលក្ខណៈសម្បត្តិបានទទួលជំនួយ ក្នុងរដ្ឋរបស់អ្នក បើទោះបីជាប្រាក់ចំណូល និងធនធានរបស់អ្នកមានតម្លៃច្រើនក៏ដោយ ។ ធនធាន មានរួមទាំងប្រាក់នៅក្នុងគណនីសែក ឬគណនីសន្សំ ប័ណ្ណភាគហ៊ុន និងប័ណ្ណប្រាក់រដ្ឋាភិបាល ។ ធនធានទាំងនោះ មិនរាប់បញ្ចូលនូវផ្ទះ រថយន្ត កន្លែងបញ្ចុះសព ការចំណាយលើការបញ្ចុះសព ទៅតាមចំនួនកំណត់របស់រដ្ឋ គ្រឿងសង្ហារិម ឬរបស់របរក្នុងផ្ទះផ្សេងៗ ទៀតឡើយ ។

សម្រាប់ព័ត៌មានបន្ថែម

■ ចូរហៅទូរស័ព្ទ ឬធ្វើដំណើរមកកាន់ការិយាល័យ State Medical Assistance (Medicaid) ហើយសួរគេអំពីព័ត៌មានចំពោះ Medicare Savings Programs ។ ឈ្មោះនៃកម្មវិធីទាំងនេះ និងវិធីដំណើរការនៃកម្មវិធីនីមួយៗ អាចខុសគ្នាទៅតាមរដ្ឋនីមួយៗ ។ ចូរហៅទូរស័ព្ទមកជួបគេ បើអ្នកគិតថាអ្នកមានលក្ខណៈសម្បត្តិបានទទួលជំនួយ ពីកម្មវិធីណាមួយ ក្នុងចំណោមកម្មវិធីទាំងនេះ បើទោះបីជាអ្នកមិនប្រាកដក្នុងចិត្តក៏ដោយ ។

■ ចូរហៅទូរស័ព្ទមកកាន់លេខ 1-800-MEDICARE (1-800-633-4227) ហើយនិយាយថា “Medicaid” ដើម្បីបានទទួលលេខទូរស័ព្ទ សម្រាប់រដ្ឋរបស់អ្នក ។ សម្រាប់អ្នកប្រើទូរស័ព្ទក្តារចុច TTY គួរហៅមកកាន់លេខ 1-877-486-2048 ។

■ ទស្សនាគេហទំព័រ http://go.usa.gov/loA ដើម្បីពិនិត្យមើលខិត្តប័ណ្ណដែលមានចំណងជើងថា “Get Help With Your Medicare Costs: Getting Started” ។ អ្នកក៏អាចហៅ

ទូរស័ព្ទមកកាន់លេខ 1-800-MEDICARE ដើម្បីចង់ដឹង ថា តើគេអាចផ្ញើរឯកសារនេះមួយច្បាប់ តាមប្រៃសនីយ៍មកឲ្យអ្នកបានដែរឬទេ ។

## Medicaid

■ Medicaid គឺជាកម្មវិធីរួមគ្នារវាងរដ្ឋ និងសហព័ន្ធ ដែលជួយចេញថ្លៃវេជ្ជសាស្ត្រ ប្រសិនបើអ្នកមានប្រាក់ចំណូល និងធនធានតិចតួច ហើយបានបំពេញល័ក្ខខ័ណ្ឌសមស្របសម្រាប់មានសិទ្ធិទទួលជំនួយផ្សេងៗទៀត ។ មានអ្នកខ្លះ មានលក្ខណៈសម្បត្តិបានទទួលជំនួយទាំង Medicare និង Medicaid ។ អ្នកទាំងអស់នេះក៏ត្រូវបានគេ ហៅផងដែរថា "អ្នកមានសិទ្ធិទទួលជំនួយពីរ" ។

■ បើអ្នកមានការធានាសុខភាពពី Medicare និងបានទទួលការគ្របដណ្តប់ទាំងស្រុងពី Medicaid គឺមានន័យថាការចំណាយមួយភាគធំ លើការថែទាំសុខភាពរបស់អ្នក ស្ទើរតែបានទទួលការគ្របដណ្តប់ទាំងអស់ទៅ

ហើយ ។ អ្នកមានជម្រើសនៅក្នុង Original Medicare (Medicare ដើម) ឬ Medicare Advantage Plan (ផែនការអត្ថប្រយោជន៍ Medicare)(ដូចជា HMO ឬ PPO) សម្រាប់ការធានារ៉ាប់រង Medicare របស់អ្នក ។

■ បើអ្នកមានការធានារ៉ាប់រងពី Medicare និង Medicaid, Medicare ផ្តល់ឲ្យអ្នកនូវការធានារ៉ាប់រង លើថ្លៃថ្នាំតាមវេជ្ជបញ្ជាជំនួសឲ្យ Medicaid ។ Medicaid អាចនៅបន្តការធានារ៉ាប់រង លើថ្លៃថ្នាំពេទ្យមួយចំនួន និងការថែទាំផ្សេងទៀតដែលមិនបានធានារ៉ាប់រងដោយ Medicare។

■ អ្នកដែលមានការធានារ៉ាប់រងពី Medicaid អាចបានទទួលការធានារ៉ាប់រងសម្រាប់ការចំណាយលើសេវានានា ដែល Medicare មិនផ្តល់ការធានារ៉ាប់រងទាំងស្រុង ដូចជាផ្ទះផ្តល់ការថែទាំអ្នកជំងឺ និងការថែទាំសុខភាពតាមផ្ទះ ។

■ កម្មវិធីMedicaid មានភាពខុសគ្នាពីរដ្ឋមួយ ទៅរដ្ឋមួយ ។ ហើយកម្មវិធីនេះ ក៏អាចមានឈ្មោះខុសៗគ្នាដែរ ដូចជា“Medical Assistance-ជំនួយវេជ្ជសាស្ត្រ” ឬ “Medi-Cal”។

■ រដ្ឋនីមួយៗ មានលក្ខខណ្ឌតម្រូវខុសៗគ្នាលើប្រាក់ចំណូល និងធនធាន ចំពោះសិទ្ធិទទួលជំនួយ Medicaid និងជំនួយផ្សេងទៀត ។

■ នៅក្នុងរដ្ឋខ្លះ អ្នកអាចត្រូវមានការធានារ៉ាប់រងពី Medicare សិន ទើបអាចមានសិទ្ធិបានទទួលការធានារ៉ាប់រងពី Medicaid ។

■ ចូរហៅទូរស័ព្ទមកកាន់ការិយាល័យ State Medical Assistance (Medicaid-ជំនួយវេជ្ជសាស្ត្ររដ្ឋ) របស់អ្នក ដើម្បីបានទទួលព័ត៌មានបន្ថែម និងដើម្បីចង់ដឹងថា តើអ្នកមានលក្ខណៈសម្បត្តិបានទទួលជំនួយដែរឬទេ ។ ចូរហៅមកកាន់លេខ 1-800-MEDICARE (1-800-633-4227) ហើយនិយាយថា “Medicaid” ដើម្បីបានទទួលលេខទូរស័ព្ទរបស់ការិយាល័យ State Medical Assistance (Medicaid) នៃរដ្ឋរបស់អ្នក ។ សម្រាប់ អ្នកប្រើទូរស័ព្ទ ក្តារចុច TTY គួរហៅមកកាន់លេខ 1-877-486-2048 ។ អ្នកក៏អាចមើលព័ត៌មានក្នុងគេហទំព័រ

www.medicare.gov ផងដែរ ។

## State Pharmacy Assistance Programs (SPAP-កម្មវិធីជំនួយឱសថស្ថានរដ្ឋ)

រដ្ឋជាច្រើន មាន State Pharmacy Assistance Programs (SPAP-កម្មវិធីជំនួយឱសថស្ថានរដ្ឋ) ដែលជួយដល់ពលរដ្ឋមួយចំនួន ក្នុងការចេញថ្លៃថ្នាំពេទ្យតាមវេជ្ជបញ្ជា ដោយសំអាងលើសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុ អាយុ ឬស្ថានភាពសុខភាព ។ SPAP នីមួយៗ មានបែបបទ អំពីរបៀបផ្តល់ការធានារ៉ាប់រងលើថ្លៃថ្នាំពេទ្យរបស់ខ្លួនរៀងៗខ្លួន ដល់សមាជិករបស់ខ្លួន ។ អាស្រ័យលើរដ្ឋរបស់អ្នក SPAP នឹងជួយអ្នកតាមវិធីផ្សេងៗ ។ ដើម្បីចង់ដឹងពី SPAP នៅក្នុងរដ្ឋរបស់អ្នក ចូរហៅទូរស័ព្ទទៅកាន់ State Health Insurance Assistance Program (SHIP-កម្មវិធីជំនួយការធានារ៉ាប់រងសុខភាពរដ្ឋ) របស់អ្នក ។

## Programs of All-Inclusive Care for the Elderly (PACE-កម្មវិធី ថែទាំទាំងអស់សម្រាប់មនុស្សចាស់)

PACE គឺជាកម្មវិធីរបស់ Medicare និង Medicaid ដែលមាន ផ្តល់ជូននៅក្នុងរដ្ឋជាច្រើន បានអនុញ្ញាតឲ្យពលរដ្ឋ ដែលត្រូវការ ការថែទាំកំរិតដាក់អោយនៅតាមផ្ទះផ្តល់ការថែទាំអ្នកជំងឺឲ្យបន្តស្ថិតនៅក្នុងសហគមន៍របស់ខ្លួនបាន។

## អត្ថប្រយោជន៍ Supplemental Security Income (SSI-ប្រាក់ចំណូលសុវត្ថិភាពបន្ថែម)

SSI គឺជាអត្ថប្រយោជន៍ជាសាច់ប្រាក់ ដែលបង់ជូនដោយកម្មវិធី Social Security ដល់ពលរដ្ឋដែលមានប្រាក់ចំណូល និងធនធានតិចតួច និងជាជនពិការ ខ្វាក់ភ្នែក ឬមានអាយុ ៦៥ឆ្នាំ ឬចាស់ជាងនេះ ។ អត្ថប្រយោជន៍ SSI ជួយឲ្យពលរដ្ឋ បានទទួលនូវសេចក្តី

ត្រូវការជាមូលដ្ឋានរបស់ខ្លួន ដូចជាចំណីអាហារ សម្លៀកបំពាក់ និងទីជម្រក ។ អត្ថប្រយោជន៍ SSI គឺមិនដូចគ្នាទៅនឹងអត្ថប្រយោជន៍ Social Security ឡើយ ។

អ្នកអាចមើលព័ត៌មានក្នុងគេហទំព័រ www.socialsecurity.gov ហើយប្រើ “Benefit Eligibility Screening Tool-ឧបករណ៍ចម្រាញ់រកមើលភាពមានសិទ្ធិទទួលអត្ថប្រយោជន៍” ដើម្បីចង់ដឹងថា តើអ្នកអាចមានសិទ្ធិបានទទួលអត្ថប្រយោជន៍ SSI ឬអត្ថប្រយោជន៍ ផ្សេងទៀតដែរឬទេ ។ ដើម្បីបានទទួលព័ត៌មានបន្ថែមចូរហៅទូរស័ព្ទទៅកាន់ Social Security តាមរយៈលេខ 1-800-772-1213 (មានអ្នកបកប្រែភាសានៅចាំជួយតាមការស្នើសុំ) ឬទាក់ទងជាមួយនឹងការិយាល័យ Social Security ប្រចាំមូលដ្ឋានរបស់អ្នក ។ សម្រាប់អ្នកប្រើទូរស័ព្ទក្តារ ចុច TTY គួរហៅមកកាន់លេខ 1-800-325-0778 ។

កំណត់ចំណាំ ៖ អ្នកដែលរស់នៅក្នុងរដ្ឋព័រតូរីកូ កោះវ៉ឺ

ជិន កោះគួម ឬអាមេរិកាំងសាម៉ូអា មិនអាចមានសិទ្ធិបានទទួលជំនួយ SSI ឡើយ ។

មានកម្មវិធីមួយចំនួននៅក្នុងរដ្ឋព័រតូរីកូ កោះវ៉ឺជិន កោះគួម និងកោះម៉ា រៀណាខាងជើង និងអាមេរិកាំងសាម៉ូអា ដើម្បីជួយដល់ពលរដ្ឋ ដែលប្រាក់ចំណូល និងធនធានរបស់ខ្លួនមានចំនួនតិចតួច ដើម្បីជួយចេញថ្លៃ Medicare របស់ពួកគេ។ នៅក្នុងតំបន់ទាំងនេះ កម្មវិធីនីមួយៗមាន  លក្ខណៈខុសៗគ្នា ។ ចូរហៅទូរស័ព្ទទៅកាន់ការិយាល័យ Medical Assistance (Medicaid) ប្រចាំមូលដ្ឋានរបស់អ្នក ដើម្បីចង់ដឹង អំពីបែបបទកម្មវិធីទាំងនោះ ឬហៅទូរស័ព្ទមកកាន់លេខ 1-800-MEDICARE (1-800-633-4227) ហើយនិយាយថា “Medicaid” សម្រាប់ព័ត៌មានបន្ថែម ។ សម្រាប់អ្នកប្រើទូរស័ព្ទក្តារចុច TTY គួរហៅមកកាន់លេខ 1-877-486-2048 ។ អ្នកក៏អាចមើលព័ត៌មានក្នុងគេហទំព័រ www.medicare.gov ផងដែរ ។

**Children's Health Insurance Program** (កម្មវិធីធានារ៉ាប់រងសុខភាពកុមារ)

តើអ្នកមានកូន ឬចៅ ដែលត្រូវការ ការធានារ៉ាប់រងសុខភាពដែរឬទេ? កម្មវិធីការធានារ៉ាប់រងសុខភាពកុមារ ផ្តល់ជូន នូវការធានារ៉ាប់រងសុខភាពដែលមានតម្លៃទាប ដល់កុមារនៅក្នុងគ្រួសារ ដែលមានប្រាក់ចំណូលច្រើនពេក ធ្វើឲ្យមិនមានលក្ខណៈសម្បត្តិក្នុងការបានទទួលជំនួយពី Medicaid តែក៏មិនអាចមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទិញការធានារ៉ាប់រងសុខភាពពីក្រុមហ៊ុនឯកជនបានដែរ ។

នៅតាមរដ្ឋមួយចំនួនធំ កុមារអាយុ ១៨ឆ្នាំ ឬក្មេងជាងនេះ ដែលមិនមានការធានារ៉ាប់រងសុខភាព ហើយដែលគ្រួសាររបស់ពួកគេ មានប្រាក់ចំណូលរហូតដល់ $៨៨១០០ ក្នុងមួយឆ្នាំ (សម្រាប់គ្រួសារដែលមានគ្នាបួននាក់) មានសិទ្ធិបានទទួលការធានារ៉ាប់រងសុខភាព ដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាប ដែលជួយចេញថ្លៃជួប

គ្រូពេទ្យ ការថែទាំធ្មេញ ថ្លៃថ្នាំពេទ្យតាមវេជ្ជបញ្ជា ការដេកពេទ្យ និងមុខចំណាយផ្សេងពីនេះទៀត ។ ស្ត្រីមានផ្ទៃពោះ និងមនុស្សពេញវ័យផ្សេងៗទៀត ក៏ប្រហែលជាអាចមានសិទ្ធិបានទទួលការធានារ៉ាប់រងនេះផងដែរ ។ រដ្ឋនីមួយៗ មានកម្មវិធីរបស់ខ្លួននិងលក្ខខ័ណ្ឌទទួលបានជំនួយរៀងៗខ្លួន ។ ដើម្បីបានដឹងព័ត៌មានបន្ថែម ចូរហៅទូរស័ព្ទទៅកាន់លេខ 1-877-KIDS-NOW (1-877-543-7669) ឬមើលព័ត៌មានក្នុងគេហទំព័រ www.insurekidsnow.gov ។

## សម្រាប់ជំនួយ សូមទាក់ទងមកកាន់ អាសយដ្ឋានដូចខាងក្រោម ៖

**Cambodian Association of Greater Philadelphia**
**(សមាគមកម្ពុជានៃមហារដ្ឋហ្វីឡាដែលហ្វៀ)**

**North Office**
**5412 N. 5th Street**
**Philadephia, PA 19120**
**(215) 324-4070**

**South Center**
**2416-18 S. 7th Street**
**Philadelphia, PA 19148**
**(215) 389-0748**

**Cambodian Association of Illinois**
(សមាគមខ្មែររដ្ឋអ៊ីលីណយ)

**2831 W. Lawrence Ave**
**Chicago, IL 60625**
**(773) 878-7090**
ទូរសារ ៖ **(773) 878-5299**

**Cambodian Mutual Assistance Association**
(សមាគមជួយគ្នាទៅវិញទៅមករបស់កម្ពុជា)

**120 Cross Street**
**Lowell, MA 01854**
**(978) 454 6200**

**United Cambodian Association of Minnesota (UCAM)**
(សមាគមរួបរួមកម្ពុជានៃរដ្ឋមីណេសូតា)

**1101 Snelling Avenue North**
**Saint Paul, MN 55108**
**(651) 222-3299**

**United Cambodian Community, Inc.**
(សហាគមន៍រួបរួមកម្ពុជា អ៊ិញ)

**2201 E. Anaheim St., Suite 200**
**Long Beach, CA 90804**
**(562) 433-2490**

សម្រាប់ជំនួយជាភាសាអង់គ្លេស អ្នកអាចហៅទូរស័ព្ទមកកាន់លេខផ្តល់ជំនួយរបស់ NAPCA តាមរយៈលេខ 1-800-336-2722

កូនសៀវភៅនេះ ត្រូវបានផលិតឡើងដោយ National Asian Pacific Center on Aging (NAPCA-មជ្ឈមណ្ឌលជាតិអាស៊ីប៉ាស៊ីភិចសម្រាប់មនុស្សចាស់) គាំទ្រដោយថវិកាសប្បុរសពី Walmart Foundation (មូលនិធិ វ៉លម៉ាត)